# ១៩.ព្រេងទាក់ទងនឹងទំនៀមពូនភ្នំស្រូវ

---

ពិធីពូនភ្នំស្រូវ គេច្រើនធ្វើនៅខែមាឃ-ផល្គុន ឬ ដើមខែចេត្រ គឺនៅពេលផុតរដូវច្រូតកាត់ ។ អ្នកស្រុក នាំគ្នាធ្វើពិធីនេះឡើង ដើម្បីផ្គត់ផ្គង់គ្រឿងបម្រុងចតុប្បច្ច័យសម្រាប់ព្រះសង្ឃ គឺគេនាំគ្នាចំណាយផលដែលធ្វើបាននោះ ម្នាក់បន្តិចៗ ប្រមូលគ្នាយកទីវេរចំពោះព្រះសង្ឃ ។

ពិធីពូនភ្នំស្រូវនេះ គេច្រើនតែនិយមធ្វើនៅក្នុងវត្ត ខាងមុខព្រះវិហារ ។ ពេលខ្លះ គេធ្វើ ៣ ថ្ងៃ, ពេលខ្លះធ្វើ ៧ ថ្ងៃ តាមកាលៈទេសៈ និងសទ្ធាជ្រះថ្លារបស់អ្នកស្រុក ។ កាលណាចប់ហើយ អាចារ្យជាអធិបតី ក្នុងកិច្ចការវត្ត ក៏ចាប់ឲ្យឧបាសក-សិកានាំគ្នាដឹកជញ្ជូនស្រូវ ដែលពូនជាភ្នំនោះ យកទៅដាក់ឃ្លាំងវត្ត ។ បុណ្យពូនភ្នំស្រូវនេះ ចាប់តាំងពីថ្ងៃ ១ រោច ខែចេត្រទៅ មិនដែលឃើញមានធ្វើទេ ។

មានសាស្ត្រាល្បែង "ស្លឹករឹត" មួយ និយាយអំពីនាងនក់ និង កឡុកបណ្ឌិត្យ ដែលទាក់ទងនឹងពិធីពូនភ្នំស្រូវ មានសេចក្តីសង្ខេបដូចតទៅ ៖

កាលដែលកន្លងទៅហើយ មានបុរសម្នាក់ឈ្មោះកឡុកបណ្ឌិត និងស្ត្រីម្នាក់ឈ្មោះនាងនក់ នៅក្នុងភូមិជាមួយគ្នា ។ កាលនៅវ័យក្មេងនៅឡើយ អ្នកទាំងពីរនាក់នេះ តែងលេងជាមួយគ្នាជាធម្មតា ។ ថ្ងៃមួយ អ្នកទាំងពីរនាក់ ក៏នឹកភ្ញកនិយាយអំពីអនាគត និងបំណងរបស់ខ្លួន ។

កឡុកបណ្ឌិតនិយាយថា "នែនាងនក់ ! អញ បើនឹងយកប្រពន្ធទាល់តែស្រីនោះ ចេះគោរពអញ តាមករណីកិច្ចជាភរិយា ហើយបើកាលណាអញទៅងូតទឹកកំពង់, ស្រីនោះ ត្រូវកាន់សំពត់ងូតតាមទៅឲ្យអញដល់កំពង់ ទើបអញយកធ្វើជាប្រពន្ធ" ។

នាងនក់ ក៏ឆ្លើយតបទៅវិញថា "បងអើយ ! ខ្ញុំក៏មានចិត្តគិតដូចបងដែរ, បើបុរសណាកាន់សំពត់ងូតខ្ញុំទៅដល់កំពង់ទឹក ហើយបម្រើខ្ញុំគ្រប់បែបយ៉ាង ទើបខ្ញុំយកធ្វើជាប្តី" ។

រំលងពីនោះបន្តិចមក កឡុកបណ្ឌិត ក៏ដល់អាយុចូលបួសក្នុងព្រះពុទ្ធសាសនា ។ លុះចាកសិក្ខាបទមកវិញ នាងនក់នោះ ក៏មិនទាន់មានប្តី, ម្តាយឪពុកកឡុកបណ្ឌិត ក៏ទៅស្តីដណ្តឹងនាងមកធ្វើជាប្រពន្ធកូនខ្លួន ឲ្យបាននៅរួមសុខទុក្ខជាមួយគ្នាតទៅ ។ កឡុកបណ្ឌិត ស្រឡាញ់ថ្នមប្រពន្ធណាស់ មិនដែលឲ្យសៅហ្មងអ្វីឡើយ ។ នាងនក់ ក៏បម្រើប្តីតាមករណីកិច្ចរបស់ខ្លួនដែរ ។

ថ្ងៃមួយ ប្តីប្រពន្ធនាំគ្នាទៅងូតទឹក ។ នាងនក់នឹកឃើញពាក្យដែលខ្លួនបាននិយាយលេងនឹងគ្នាកាលពីក្មេង លុះងូតរួច ក៏ឡើងត្រឡប់ទៅផ្ទះមិនប្តី ធ្វើជាភ្លេចក្រមា ។ កឡុកបណ្ឌិត ឃើញប្រពន្ធភ្លេចក្រមាងូតទឹក ខំស្រែកប្រាប់ ។ នាងនក់ប្រាប់ទៅវិញថា "បងកាន់យកមកឲ្យខ្ញុំផង !" ។ កឡុកបណ្ឌិត ក៏កាន់យកក្រមាងូតទឹករបស់ប្រពន្ធទៅផ្ទះ ។ ទៅដល់ផ្ទះហើយ នាងនករៀបបាយទឹកជូនប្តីបរិភោគរួចស្រេច, ពេលចូលដំណេក សំណេះសំណាលពីនេះពីនោះ នាងនក ក៏និយាយចំអន់ប្តីលេងថា "នែបង ! បងភ្លេចហើយឬនៅ ? កាលយើងនៅពីក្មេងទាំងអស់គ្នា ខ្ញុំបាននិយាយនឹងបងថា "បើខ្ញុំយកប្តី ទាល់តែប្តីនោះបម្រើ ហើយកាន់

ក្រមាង្វតទឹកឲ្យខ្ញុំ ទើបខ្ញុំយកជាប្តី ឥឡូវនេះ ខ្ញុំបានប្តីកាន់ក្រមាង្វតទឹកឲ្យមែន សមតាមបំណាងរបស់ខ្ញុំហើយ" ។ កឡុកបណ្ឌិត ស្តាប់ប្រពន្ធនិយាយដូច្នោះ នឹកឃើញរឿងដើម ក៏កើតសេចក្តីខ្មាសអៀននឹងពាក្យប្រពន្ធ នឹកក្នុងចិត្តថា "មិនគួរចាញ់ប្រៀបមនុស្សស្រីសោះ" ។ ហើយក៏ឈប់និយាយលេងតទៅទៀត ។ ប្រពន្ធមិនដឹងជាប្តីអន់ចិត្តនឹងសម្តីខ្លួន ក៏និទ្រាលក់ទៅ ។ កឡុកបណ្ឌិត ក៏លបលួចយកសំពៅមួយ ធ្វើដំណើររត់ចេញទាំងយប់ ។ លុះព្រឹកឡើង ទៅដល់នគរមួយ ដែលមានស្តេចសោយរាជ្យមាននាមថា "ស្តេចបំផ្លាញឈ្មួញ" ។ លុះដឹងថាមានសំពៅមួយមកចតនៅតំបន់ខ្លួន ស្តេចនោះត្រេកអរណាស់ ទើបប្រើសេនារៀបភោជនាហារ ជប់លៀងកឡុកបណ្ឌិតជានាយសំពៅ ដោយចាត់ឲ្យមានមនុស្សបម្រើពុំមានខ្វះ ។ ទ្រង់សំណេះសំណាលរាក់ទាក់នឹងនាយសំពៅ ហើយឃាត់ឲ្យនាយសំពៅនៅកម្សាន្តបានពីរ-បីថ្ងៃសិន ។ នៅពេលដែលកឡុកបណ្ឌិតកំពុងតែបរិភោគអាហារ ស្តេចបំផ្លាញឈ្មួញនោះ ក៏ចាត់បម្រើឲ្យយកអណ្តើកមាសមួយទៅលាក់ក្នុងសំពៅ ។

ពីរបីថ្ងៃក្រោយមក កឡុកបណ្ឌិត ក៏ឡើងទៅក្រាបបង្គំលាស្តេចចេញដំណើរទៅទៀត ។ ស្តេចនោះ ស្រាប់តែចោទប្រកាន់កឡុកបណ្ឌិតថា "នែមាណព ! យើងរាប់អានស្រឡាញ់ឯង ឃាត់ឯងឲ្យនៅកម្សាន្តបានពីរបីថ្ងៃ មិនគួរឯងមានគំនិតអាក្រក់ មកលួចទ្រព្យសម្បត្តិដែលជាកេរមតិកយើងទៅសោះ !" ។ ឯងចេញទៅមិនទាន់បានទេ ចាំយើងរើរកមើលទ្រព្យយើងសិន !" ។ កឡុកបណ្ឌិត មិនដឹងកលស្តេចបំផ្លាញឈ្មួញ ក៏ទូលតបថា "សូមចាត់បម្រើឲ្យរើមើលចុះ បើឃើញទ្រព្យអ្វីជារបស់ព្រះអង្គពិតប្រាកដ ខ្ញុំព្រះអង្គ សូមនៅជារាជបម្រើ ហើយប្រគល់ទាំងសំពៅ និងឥវ៉ាន់ ដែលផ្ទុកក្នុងនោះទាំងប៉ុន្មាន ថ្វាយព្រះអង្គទៀត ។

ស្តេចបំផ្លាញឈ្មួញ ក៏ចាត់បម្រើឲ្យរើភ្លាម លុះឃើញអណ្តើកមាសហើយ ក៏រឹបអូសយកសំពៅ ព្រមរបស់ទ្រព្យ រួចដាក់កឡុកបណ្ឌិតជាបម្រើ តាមកិច្ចសន្យា ។

ថ្លែងពីនាងនក ព្រឹកឡើង រកប្តីមិនឃើញ ក៏ឆាឡោ ចាត់បម្រើឲ្យដើររក ។ លុះដឹងថាបាត់សំពៅមួយ ទើបនាងយល់ជាក់ថា ប្តីច្បាស់ជារត់ចោលនាងហើយ ព្រោះតែពាក្យសំដីដែលនាងនិយាយចំអន់លេងពីល្ងាចនោះ ។ នាងនក ក៏រៀបចំឥវ៉ាន់ដាក់សំពៅ ធ្វើដំណើរចេញទៅតាមប្តី ដោយរកទាំងសារិកាដែលនាងចិញ្ចឹមទៅផង ។ លុះទៅដល់នគរស្តេចបំផ្លាញឈ្មួញ នាងក្រឡេកទៅឃើញស្គាល់ជាសំពៅប្តីនាង ទើបនាងខំគន់រកមើលប្តី តែមិនឃើញសោះ ព្រោះគេចាត់ឲ្យទៅធ្វើការនៅទីដទៃឆ្ងាយ ។ នាងក៏សំចតនៅទីនោះសិន ចាំស៊ើបការណ៍មើល ។ ឯស្តេចទុច្ចរិត កាលឃើញសំពៅពោរពេញទៅដោយទំនិញផ្សេងៗ មកដល់ទៀត នឹកអរ ក៏ធ្វើល្បិចដូចមុន ។ លុះដល់នាង និងបរិវារចេញទៅទទួលការជប់លៀងរបស់ស្តេច ពួករាជបម្រើ ក៏យកអណ្តើកមាសទៅលាក់ដូចមុនទៀត ។ ប៉ុន្តែ សារិកាដែលទំនៅលើដងក្តោងខ្ពស់ បានឃើញការពុំគួរទាំងអស់ ។ លុះម្ចាស់វិលមកវិញ វាក៏ប្រាប់តាមដំណើរដែលឃើញ ។ នាង ក៏ចាត់បម្រើឲ្យយកអណ្តើកទៅចងពន្លិចក្នុងទឹកភ្លាម ។ នៅយូរថ្ងៃគន់មើលប្តីមិនឃើញ នាងក៏ឡើងទៅលាស្តេច ដើម្បីចេញដំណើរទៅទៀត ។ ស្តេចបំផ្លាញឈ្មួញ ក៏តាំងចោទនាងដូចលើកមុនទៀត ។ នាងនក់សន្យានឹងស្តេចថា បើកាលណារកទៅឃើញឥវ៉ាន់របស់ស្តេចនៅក្នុងសំពៅនាង នាងសុខចិត្តថ្វាយជីវិត និងសំពៅ ព្រមទាំងរបស់ដែលផ្ទុកក្នុងសំពៅ ។ ជាភ័ព្វល្អដល់នាង ស្តេចនោះក៏ថ្លោយព្រះឱស្ឋប្តេជ្ញានឹងនាងថា បើកាលណារកទៅមិនឃើញរបស់ទ្រព្យអ្វីនៅក្នុងសំពៅនាងទេ ស្តេចសុខចិត្តផ្ទេររាជសម្បត្តិ និងខ្ញុំកំដរទាំងអស់ឲ្យនាង ។ និយាយខខិតនឹងគ្នារួចហើយ ស្តេចក៏ចាត់បម្រើឲ្យចុះ ក្នុងសំពៅភ្លាម តែពុំឃើញអណ្តើកមាសនោះសោះ ទើបសុខចិត្ត

ផ្ទេររាជ្យតាមពាក្យប្ដេជ្ញា ។ នាងនក់មិនព្រមទទួលរាជ្យនោះទេ នាងសុំយកតែសំពៅ ៥ ដែលផ្ទុកដោយទំនិញពេញ និងសុំរើសអ្នកបម្រើម្នាក់ ។ ខណៈនោះ ស្ដេចក៏សុខចិត្តធ្វើតាម ហើយក៏ទ្រង់បង្គាប់ឲ្យប្រជុំខ្ញុំកំដរ ដែលចាត់ទៅទាំងជិតឆ្ងាយ ឲ្យចូលមកដើម្បីនាងរើស ។ ពេលនោះ នាងក៏បានឃើញប្ដីស្លៀកពាក់អាវកណ្ដោចកណ្ដាចស្ទើរតែមើលមិនស្គាល់ ទើបនាងទូលស្ដេចថា "សុំយកមនុស្សបម្រើម្នាក់ គឺ កឡុកបណ្ឌិតនេះឯង", ហើយទើបចាត់ឲ្យជញ្ជូនឥវ៉ាន់ដាក់ពេញសំពៅទាំង ៥ ។ នាយកឡុកបណ្ឌិត លុះឃើញប្រពន្ធមកតាមជួយខ្លួនឲ្យរួចអំពីទុក្ខទោស ត្រេកអរពន់ពេក ក៏សុំឲ្យនៅលេងទីនោះមួយយប់ទៀត ។

និយាយពីស្ដេចទុច្ចរិត លុះធ្វើការមិនបានសម្រេចដូចបំណង កើតក្ដៅក្រហាយ មិនអស់ចិត្ត ក៏ហៅបរិវារដែលយកអណ្ដើកមាសទៅលាក់មកសួរបញ្ជាក់ ។ បរិវារបង្គំទូលថា កាលដែលខ្ញុំព្រះអង្គយកទៅលាក់ គ្មានឃើញអ្នកណាទេ ឃើញតែសត្វសារិកាមួយទំលើដងក្ដោង ។ ឮតែប៉ុណ្ណោះ ស្ដេចពាលក៏យល់ការណ៍ ទើបបង្គាប់ឲ្យទៅបញ្ឆោតចាប់សារិកានោះមកសម្លាប់ចោល ។ ពួកបរិវារ ក៏ទៅចាប់បានសារិកាយកមកថ្វាយស្ដេច ៗ បញ្ជាឲ្យដករោមម្ដងមួយៗ រួចសឹមឲ្យវាសម្លាប់ ។ បរិវារអ្នកសម្លាប់សារិកានោះ ប្រុងនឹងប្រឡាក់អាំងស៊ី តែភ្លេចយកអំបិលមក ក៏ទុកសារិកានោះនៅកន្លែងមួយ ហើយរត់ទៅយកអំបិលមក សារិកានោះមិនទាន់ស្លាប់ទេ គ្រាន់តែសន្លប់ លុះភ្ញាក់ស្មារតីដឹងខ្លួនឡើង ក៏ខំលោតចូលទៅពួនក្នុងរន្ធគល់ឈើមួយនៅក្បែរនោះ ។ បរិវារដែលរត់ទៅយកអំបិល លុះត្រឡប់មកវិញ រកសារិកាមិនឃើញក៏ហីទៅ ។

រីឯកឡុកបណ្ឌិត និងនាងនក់ លុះរៀបចំដំណើរចេញទៅ រកសារិកាមិនឃើញ ក៏ប្រើបម្រើឲ្យដើររក តែមិនឃើញទៀត ទើបចាត់ការចេញសំពៅទៅ ។

ចំណែកឯសត្វសារិកា ដែលពួននៅក្នុងរូងឈើនោះ លុះយប់ស្ងាត់ ឃើញស្ដេចកណ្ដុរសមួយចេញដើររកអាហារ ក៏សាកសួរគ្នា ហើយសុំឲ្យកណ្ដុរសជួយកាយរូងមួយ សម្រាប់នៅបណ្ដោះអាសន្ន ទម្រាំដុះរោមពេញ នឹងបានសងគុណឲ្យគាប់ចិត្ត ។ ស្ដេចកណ្ដុរស ក៏ព្រម ។ មួយខែកន្លងមក សារិកា ក៏ដុះរោមពេញដូចដើម ហើយគិតរកមធ្យោបាយសងគុណគេវិញ,ទើបនិយាយទៅកាន់ស្ដេចកណ្ដុរសថា " សូមលោកជួយកាយរូងមួយទៅដល់វត្ត ហើយធ្វើរន្ធបង្ហុយចេញតាមព្រះឱស្ឋព្រះជីវ៍ធំក្នុងព្រះវិហារ ឲ្យមានប្រឡោះល្មមបញ្ចេញសំឡេងបាន ។ ស្ដេចកណ្ដុរស ក៏ទទួលធ្វើតាម ។ លុះធ្វើស្រេចហើយ សារិកា ក៏ចូលទៅនៅសម្ងំចាំលុះឃើញសាមណេរមួយអង្គចូលទៅទន្ទេញធម៌នៅក្នុងព្រះវិហារនោះ វាក៏បញ្ចេញសំឡេងក្លែងធ្វើជាព្រះចេះនិយាយថា

“នែ ! សាមណេរ ! នៅទន្ទេញធម៌ដល់ណាទៀត ! ម្ដេចមិនទៅប្រាប់អាចារ្យឲ្យប្រមូលគ្នាមកធ្វើបុណ្យភ្ជុំស្រូវទាន់អញតថាគតនៅ" ។

សាមណេរឮដូច្នោះ ភ័យណាស់ រត់ទៅពិតលោកគ្រូចៅអធិការ ៗមកមើល លុះឮពាក្យដដែលមែន ក៏ចេញទៅទូងស្គរ ហៅអ្នកស្រុកឲ្យប្រជុំគ្នាធ្វើបុណ្យភ្ជុំស្រូវកំណត់ ៧ ថ្ងៃ ។ អ្នកស្រុក នាំគ្នារែកស្រូវនំនែកផ្លែឈើផ្សេងៗ ទៅចាក់គរធារក្នុងព្រះវិហារ ហើយធ្វើពិធីបុណ្យតាមលំនាំសាសនា យ៉ាងអ៊ឹកធឹក ។ សត្វសារិកាបានឱកាសហើយ ក៏ទៅប្រាប់ស្ដេចកណ្ដុរសថា "ចូរលោកនាំគ្នាទៅជញ្ជូនគ្រឿងសម្រាប់បរិភោគនោះ មកទុកដាក់បម្រុងជាស្បៀងចុះ, ខ្ញុំសុំលាលោកទៅរកម្ចាស់ខ្ញុំហើយ !” ។

ក្រោយពីនោះមក តែដល់ថ្ងៃខួបនោះ អ្នកស្រុក ក៏ចេះតែនាំគ្នាធ្វើបុណ្យភ្ជុំស្រូវ ជាប់ជាទំនៀមរហូតមក ។